D24861
(DC-Cam)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## បទសម្ភាសន៍ ហ៊ីម ហ៊ុយ

## អតីតអនុប្រធានកងការពារអ្នកទោសមន្ទីរស-២១

## នៅថ្ងៃសុក្រទី៤ ខែមករា ឆ្នាំ២០០២

## នៅក្រុងភ្នំពេញ

## ដោយ ហ៊ុយ វណ្ណៈ

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីរឿងរ៉ាវរបស់ពូដែលធ្លាប់បានធ្វើការនៅស-២១ នៅទួលស្លែង ។ ខ្ញុំចង់សួរពីអារម្មណ៍របស់ពូផ្ទាល់ ។ តើពូគិតថាអ្វីដែលពូធ្លាប់បានជួបប្រទះនៅទីនោះ ពូចង់បំភ្លេចចោល ឬក៏ពូគិតថាយ៉ាងម៉េចដែរ?

ហ៊ុយ កាលខ្ញុំធ្វើការនៅនោះ ខ្ញុំនិយាយត្រង់គឺខ្ញុំអត់ចង់ធ្វើទេ ខ្ញុំសុំគេចេញព្រោះគិតឃើញថាកន្លែងពិបាក ខ្ញុំសុំគេចេញពីណឹងតែគេមិនឲ្យខ្ញុំចេញទៀត ។ គ្មានអ្នកណាហ៊ានឡើងឈរសុំគេទេ មានតែខ្ញុំទេដែលដាច់ចិត្តសុំគេ ព្រោះនៅកន្លែងណឹងខ្លាចស្លាប់ព្រោះឃើញស្លាប់បន្តកន្ទុយគ្នាចឹង ខ្ញុំគិតវែងឆ្ងាយខ្លួនឯង ។ គ្មានការជ្រើសរើសទេ មានតែសុំគេទៅទ័ព ។ បើទៅច្បាំងស្លាប់ក៏ស្លាប់ចុះកុំឲ្យតែគេចាប់ខ្ញុំដាក់គុក ព្រោះឃើញគេដាប់វេទនាណាស់ ។ ចឹងបានសេចក្ដីថា អារម្មណ៍របស់ខ្ញុំនឹកឃើញខ្លួនឯងថា ខ្លួនឯងចង់លួចង់ស្អាតស្អំ ហេតុអីសុំគេចេញគេមិនឲ្យចេញ ។ បើដូចច្បាប់ឥឡូវនេះវិញគឺខ្ញុំអត់នៅធ្វើទេ គឺខ្ញុំត្រូវតែឈប់ ហើយទៅធ្វើស្រូវធ្វើចម្ការជាមួយម៉ែឪខ្ញុំវិញ ។ ដល់សម័យណឹងគឺសុំគេមិនបាន គេមិនឲ្យចេញ ។ ចឹងការជ្រើសរបស់ខ្ញុំ មានការពិបាកជ្រើសរើសណាស់ ។ អារម្មណ៍នឹកគិតថា ឯងធ្វើអីខុសគេស្ដីបន្ទោស ដេរម៉ែឪ ។ ខ្ញុំប្រុងបាញ់ខ្លួនឯងប៉ុន្មានដងហើយ កុំអីខ្ញុំមិនបានមកជួបជាមួយបងប្អូនទេ គឺចប់រឿងបាត់ហើយ ប៉ុន្តែខ្ញុំខ្លាចគេសម្លាប់ម៉ែឪបងប្អូនខ្ញុំអស់ ពេលដែលខ្ញុំបាញ់ខ្លួនឯង ។ ចឹងខ្ញុំចេះតែទ្រាំនៅរហូតដល់គេដកខ្ញុំឲ្យទៅធ្វើស្រែនៅឆ្ងាយ ប៉ុន្តែក៏នឹកឃើញថាមិនដឹងជាគេចាប់ខ្ញុំដាក់គុកថ្ងៃណា គេសម្លាប់ខ្ញុំចោលថ្ងៃណា ចេះតែនៅៗ ព្រោះមិនដឹងទៅណាទៀតទេ បើគេមិនឲ្យចេញ រហូតដល់ខ្ញុំមានឈ្មោះថាជា“អ្នកនៅមន្ទីរស-២១” ។

អារម្មណ៍របស់ខ្ញុំសព្វថ្ងៃក៏ខ្ញុំនៅតែគិតថា ខ្ញុំគ្មានចង់ធ្វើអ្វីឲ្យខុសទេ តែមកពីពួកគេជាអ្នកកៀបសង្កត់ពួកខ្ញុំឲ្យខ្ញុំបម្រើការងាររបស់គេ ។

វណ្ណៈ ពូយល់ថា អ្នកដែលគាបសង្កត់ពូគឺអ្នកណាខ្លះ?

ហ៊ុយ អ្នកកៀបសង្កត់គឺ តាហ៊ិ និង តាឌុច ហើយម្នាក់ទៀតដូចជា ផល នេះប្អូនខ្ញុំទេ តែហៅខ្ញុំ "អា" ។ គេធំជាងខ្ញុំ ខ្ញុំហៅគេបង ។

វណ្ណៈ ពេលដែលពូនិយាយដល់រឿងខ្មែរក្រហម ពីការងារដែលពូធ្វើ និយាយរឿងរាវទាំងឡាយក្នុងរបបខ្មែរក្រហម ពូមានអារម្មណ៍យ៉ាងម៉េចដែរ?

ហ៊ុយ ខ្ញុំគ្មានអារម្មណ៍អីទេ ព្រោះបើរឿងរាវអីខ្ញុំនិយាយប្រាប់ចឹង ។

វណ្ណៈ សម្រាប់ពូ រឿងខ្មែរក្រហម ពូចង់និយាយប្រាប់គេ ឬក៏ក្នុងចិត្តពូមិនចង់និយាយប្រាប់គេទេ?

ហ៊ុយ ចង់និយាយប្រាប់គេ ។

វណ្ណៈ ហេតុអីបានជាពូចង់?

ហ៊ុយ ព្រោះរឿងណាឹងទុកវាមិនបានគឺត្រូវតែនិយាយ ។

វណ្ណៈ ពេលដែលពូនិយាយចេញមកពូទទួលបានអ្វីខ្លះ?

ហ៊ុយ បានធូរទ្រូង ។

វណ្ណៈ ចុះបើពូមិននិយាយវិញ យ៉ាងម៉េចដែរ?

ហ៊ុយ ខ្ញុំអត់ទុកទេ ខ្ញុំត្រូវតែនិយាយ ។

វណ្ណៈ ខ្ញុំចង់ដឹងពីគំនិតរបស់ពូ តើពូចង់ឲ្យគេដឹងពីអតីតកាលរបស់ពូ ពីការងារដែលពូធ្វើ ក៏ដូចជាអតីតកាលរបស់ខ្មែរក្រហមដែរ?

ហ៊ុយ បាទ! ខ្ញុំនិយាយ ។ នៅក្នុងស្រុកភូមិក៏ខ្ញុំនិយាយប្រាប់គេដែរ ខ្ញុំអត់អត់លាក់ទេ ខ្ញុំនិយាយទាំងអស់ ។

វណ្ណៈ ចឹងពូចង់ឲ្យប្រជាជននៅក្នុងភូមិឃុំដឹងពីអតីតកាលរបស់ពូ?

ហ៊ុយ បាទ! គេដឹងទាំងអស់ ។

វណ្ណៈ ពេលដែលគេដឹងថាពូធ្វើការនៅមន្ទីរស-២១ ធ្វើការឲ្យរបបខ្មែរក្រហម កន្លែងសម្លាប់ តើគេមានអារម្មណ៍អីចំពោះពូដែរ?

ហ៊ុយ ខ្ញុំនិយាយប្រាប់គេរឿងដំណើរទំនង ចុះបើអ្នកស្រុក... គិតទៅនៅក្នុងតំបន់២៥ នេះទូទៅមិនបាច់និយាយថានៅភូមិនេះ ភូមិនោះទេ គឺគេប្រមូលទាំងអស់បងប្អូនអ្នកណាក៏ដោយឲ្យតែមានអាយុល្មមចូលធ្វើទ័ព ។ គឺថារបបណឹងពិបាកណាស់ ទាំងយើងទាំងគេគ្មានអ្នកណាចង់ធ្វើចឹងទេ តែយើងគិតមើល៍ បងប្អូនម្នាក់ ពីរនាក់ បីនាក់ បាត់បង់អស់ ។ ម៉ែឪនៅផ្ទះនៅសម្បែងនេះក៏អត់រហេមរហាម ។ ម៉ែឪខ្ញុំមិនដែលអត់វេទនាទេ មកដល់អាពតវេទនា ។

វណ្ណៈ ចឹងពេលដែលពូនិយាយប្រាប់អ្នកស្រុក គេមានអារម្មណ៍យ៉ាងម៉េចដែរជាមួយពូ?

ហ៊ុយ គេរស់នៅក្នុងរបបណឹងដែរ ចឹងការពិបាកវេទនាគេឃើញចឹង គេថាវាជាការធម្មតាទេ បើយើងមិនធ្វើតាមគេគឺគេវាយយើងចោល ។ ខ្ញុំនិយាយប្រាប់គេចឹង ខ្ញុំសុំគេចេញពីណឹងតែគេអត់ឲ្យខ្ញុំចេញ តើឲ្យខ្ញុំទៅណា! ។ សុំគេរើសតែផ្លូវមួយទេគឺទៅធ្វើទ័ព ខ្ញុំសុខចិត្តស្លាប់នៅលើសមរភូមិ ។

វណ្ណៈ ពូដែលនិយាយប្រាប់មនុស្សដែលកើតទាន់សម័យខ្មែរក្រហម ហើយមនុស្សមួយចំនួនទៀតដែលកើតមិនទាន់សម័យខ្មែរក្រហម ។ ចំពោះមនុស្សដែលកើតទាន់ក្នុងសម័យខ្មែរក្រហមគេមិនថាអីឲ្យពូទេ ។ ចុះអ្នកដែលកើតក្រោមសម័យខ្មែរក្រហម គេមានដែលចំអកឡកឡឺយឬក៏គេស្អប់ពូ ឬក៏ថាអីឲ្យពូដែរ?

ហ៊ុយ គេមិននិយាយ ព្រោះគេកើតមិនទាន់ជំនាន់ណឹង ។ ប៉ុន្តែយើងក៏ត្រូវតែនិយាយប្រាប់គេ ក៏ដូចជាកូនចៅខ្ញុំចឹងថា អ្ហែងសំណាងហើយដែលកើតក្នុងសម័យនេះ បើដូចជំនាន់អាពតអ្ហែងវេទនា ។ កើតម៉ោគេមិនឲ្យអ្ហែងនៅជាមួយម៉ែឪទេ គឺអ្ហែងត្រូវទៅរែកអាចម៍គោ ហើយរៀនសូត្រក៏មិនបានដូចឥឡូវដែរ គ្រូចេះស្ទើរៗ ចេះតែបង្រៀនបានតែត្រឹមមើលរូចទេត្រង់ថាចេះទៅធ្វើស្អីតទៅទៀតអត់ទេ ។

វណ្ណៈ ពូមានដែលនិយាយរឿងអតីតកាលរបស់ពូប្រាប់ដល់កូនរបស់ពូដែរ?

ហ៊ុយ បាទ! ខ្ញុំប្រាប់ ។ ហីចុះទុកធ្វើអី ប្រាប់វាទៅឲ្យវាដឹងឲ្យអស់ ។

វណ្ណៈ ពេលដែលពូប្រាប់ កូនពូគិតយ៉ាងម៉េចដែរ?

ហ៊ុយ វាអត់និយាយ ។ វាមិននិយាយជាមួយខ្ញុំផង ។

វណ្ណៈ សម្រាប់ពូមើលទឹកចិត្តរបស់កូនពូ តើកូនពូស្អប់ពូឬក៏ធម្មតា?

ហ៊ុយ មិនដែលមើលគ្នាផង ។

វណ្ណៈ ប៉ុន្តែពូធ្លាប់និយាយប្រាប់ថាពូធ្លាប់ធ្វើការ?

ហ៊ុយ និយាយប្រាប់នៅនឹងវង់បាយ ដូចថាទៅធ្វើចម្ការ ឬក៏នៅផ្ទះជុំគ្នា ។

វណ្ណៈ ពូនិយាយប្រាប់យ៉ាងម៉េចខ្លះ?

ហ៊ុយ និយាយប្រាប់រឿងថា របបខ្មែរក្រហមវារបៀបម៉េច របបឥឡូវរបៀបម៉េច ការស៊ីចុក ការរស់នៅ ។ ដូចខ្ញុំនិយាយប្រាប់មុនចឹង រឿងខ្ញុំគឺខ្ញុំមិនចង់នៅណឹងទេ បើចង់នៅណឹងខ្ញុំមិនបានរត់ពីព្រៃមកផ្ទះវិញទេ ។

វណ្ណៈ ពូមានដែលនិយាយរឿងណាមួយដែលពូធ្លាប់បានធ្វើលើអ្នកទោសនិយាយប្រាប់កូនរបស់ពូដែរ?

ហ៊ុយ ខ្ញុំគ្មានទៅធ្វើជាមួយគេទេ ។

វណ្ណៈ ពូនិយាយតែពីការដឹកនាំរបស់របបណឹងប្រាប់កូនពូ?

ហ៊ុយ បាទ!

វណ្ណៈ ចុះប្រពន្ធរបស់ពូ ពូមានដែលនិយាយប្រាប់ដែរ?

ហ៊ុយ ណឹងខ្ញុំក៏ប្រាប់ ។

វណ្ណៈ រហូតដល់ពេលណាបានពូនិយាយប្រាប់?

ហ៊ុយ ប្រាប់តាំងពីបានជួបគ្នារហូតមក ។

វណ្ណៈ បងស្រីមានអារម្មណ៍យ៉ាងម៉េចដែរ?

ហ៊ុយ គ្មានថាម៉េចបើរបបគេវាចឹង ។ គ្នាក៏អស់បងប្អូនគ្នាដែរ ។

វណ្ណៈ ពូមានកូនទាំងអស់ប៉ុន្មាននាក់?

ហ៊ុយ ខ្ញុំ៩នាក់ ស្រី៣នាក់ ប្រុស៦នាក់ ។ កូនបងប្រុស ។

វណ្ណៈ ពូយល់ឃើញថា ការងាររបស់ពូនៅស-២១យ៉ាងម៉េចដែរ?

ហ៊ុយ មិនដឹងនិយាយថាយ៉ាងម៉េច គេឲ្យធ្វើអីធ្វើណឹង ។ បើគេមិនឲ្យធ្វើយើងម៉ោងដេក យើងដេក ពេលពលកម្មមើលសត្វធាតុ ដាំចេក អ្វីដែលគេប្រគល់ឲ្យយើងមើល យើងធ្វើ យើងចេះតែធ្វើទៅ ។

វណ្ណៈ ពូមើលឃើញថាការងារដែល ឌុច ចាត់ឲ្យធ្វើទៅលើអ្នកទោស ទៅលើកម្មាភិបាលទាំងអស់ជាការងាររបៀបម៉េច ហើយពូយល់ថាប្រភេទការងារណឹងគួរធ្វើចឹងដែរឬអត់?

ហ៊ុយ	មិនគួរធ្វើទេការងារណឹង តែគេឲ្យយើងធ្វើ បើយើងមិនធ្វើគេវៃយើងចោល ។ ដូចខ្ញុំដឹងរាប ចឹង គ្នាប៉ុន្មានរយនាក់ នៅសល់តែប៉ុន្មាននាក់ គេជម្រុះចោលចង់អស់ ។

វណ្ណៈ	ខ្ញុំដឹងថាពូធ្វើការនៅមន្ទីរស-២១ ពូនៅផ្នែកទៅចាប់អ្នកទោស ។ មុនពេលពូទៅចាប់ អ្នកទោស និងពេលទៅចាប់អ្នកទោស ក្នុងចិត្តពូគិតយ៉ាងម៉េចដែរចំពោះអ្នកទោស ចំពោះ មនុស្សដែលពូត្រូវចាប់?

ហ៊ុយ	ទៅចាប់មនុស្សដូចថានៅក្នុងកងពលរបស់យើងចឹង យើងស្គាល់គេដូចថានៅក្នុង៧០៣ចឹង យើងទៅមិនដឹងជាប៉ះអ្នកណាមួយ ហើយមិនដឹងជាអ្នកណាឆ្លើយដាក់វិញខ្លះ ព្រោះឯកសារ អស់ណឹងក៏ខ្ញុំអត់ដឹងដែរ ។ មិនដឹងជាគេឆ្លើយដាក់អ្នកណាមួយក៏ខ្ញុំអត់ដឹងដែរ ។ មិនដឹងជា ឆ្លើយដាក់ខ្ញុំឬយ៉ាងម៉េច ។ ដូចពួកកងវរយដែលជាប់គុកមុនៗ ក៏ដោយសារឆ្លើយពីកងពល ដែលឆ្លើយចេញពីកងពលនេះទៅវិញដែរ ។ ទៅដល់ណោះគេអត់ឲ្យអ្នកនៅកងពលជាមួយ គ្នាសួរទេ គេបំបែកឲ្យទៅខាងផ្សេង ដូចថាខាងក្រុមតាឌុច ម៉ាពួកគេសួរ ព្រោះគេចង់ដឹង ថាយើងនៅមានទាក់ទងខាងក្នុងយ៉ាងម៉េចៗទៀត ។ អារម្មណ៍របស់ខ្ញុំគឺនៅតែគិតចឹង ។

វណ្ណៈ	ពូគិតជាងគេ គិតថាយ៉ាងម៉េច?

ហ៊ុយ	គិតថា ខ្លាចតែគេឆ្លើយដាក់ គេចាប់ដាក់គុក ។

វណ្ណៈ	ប៉ុន្តែពេលដែលពូចេញទៅចាប់ ពូគិតក្នុងចិត្តថាត្រូវតែទៅចាប់អ្នកណឹង ឬក៏ក្នុងចិត្តមួយគិត ផ្សេងទៀតចំពោះមនុស្សដែលត្រូវចាប់?

ហ៊ុយ	ពេលចាប់គឺមាន តាហ៊ី គាត់ទៅជាមួយ ។ គេហៅយើងទៅជាមួយ ។ ឥឡូវគ្នាអ្ហែង៤,៥ នាក់ទៅជាមួយអញ ។ ប៉ុន្តែយើងអត់មានដឹងថាចាប់អ្នកណាទេ ទៅដល់កន្លែងបានគេប្រាប់ យើង ។ បើយើងមិនចាប់ ក៏មានពួកគេខាងណោះចាប់ឲ្យ ហើយយើងគិតតែចាំទទួលពីគេ ណោះឲ្យម៉ោ ។ ភាគច្រើនគឺគេចាប់ឲ្យ ។

វណ្ណៈ	ហើយពូគិតថា អ្នកដែលចាប់មកសុទ្ធតែមានកំហុស ជាសេ.អ៊ី.អា ជាកា.ហ្សេ.បេដែលពួក ណឹងចោទ?

ហ៊ុយ	អត់ដឹងទេ គេអត់ឲ្យយើងដឹងថា អ្នកនេះមានរឿងអី មានការទាក់ទងជាមួយអ្នកណា គេឲ្យ តែយើងចាប់ ។ មកដល់ទៀតក៏គេមិនមែនឲ្យយើងសួរដឹងរឿងទេ គេឲ្យតែពួកសួរចម្លើយ សួរ ព្រោះអ្នកទៅចាប់គេអត់ឲ្យដឹងទាំងអស់ ។

វណ្ណៈ ពេលដែលពូទៅចាប់មានករណីតដៃអី មានការធ្វើទារុណកម្មយ៉ាងម៉េចដែរ?

ហ៊ុយ គអីបើពីរនាក់ចាប់ម្នាក់ គ្មានអីតទេ។

វណ្ណៈ ចឹងពេលពូទៅចាប់អត់មានករណីតដៃទេ?

ហ៊ុយ អត់ដែលទេ មានតែរើ តែរើអត់រួច។ ដូចខ្ញុំថាចឹង បើចាប់ម្នាក់ក៏មិនមែនយើងទៅចាប់តែម្នាក់ឯងដែរ គឺទៅគ្នា២នាក់។ ក្នុងអ្នកទោសម្នាក់ចាប់គ្នា២នាក់ ចឹងរើម៉េចរួច។ បើម្នាក់ទល់ម្នាក់អាចរើកើត ហើយចាប់បានវៃខ្នោះដាក់ដៃម៉ោក្រោយ ហើយចងមុខ។

វណ្ណៈ ពេលដែលទៅចាប់ ពូមើលឃើញថាមនុស្សណឹងគួរឲ្យចាប់ឬក៏យ៉ាងម៉េចដែរ?

ហ៊ុយ ខ្ញុំមិនដឹងនិយាយថាយ៉ាងម៉េច! ដឹងទទួលពីបញ្ជាគេឲ្យចាប់។

វណ្ណៈ មួយថ្ងៃៗពូខ្វល់ខ្វាយនឹងការងារដែលពូចេញទៅចាប់ជាប្រចាំ ឬក៏ខ្វល់ពី?

ហ៊ុយ ខ្វល់ខ្វាយខ្លាចតែគេឆ្លើយដាក់។ តែឆ្លើយដាក់ គេចាប់យើងដាក់គុក។ ឃើញគេវេទនានឹកឃើញថា មិនដឹងជាថ្ងៃណាគេចាប់អញដាក់គុកទេ ព្រោះនៅក្នុងនេះអស់គ្នាច្រើនហើយនឹកឃើញរហូតទល់សព្វថ្ងៃ។

វណ្ណៈ ពូឃើញអ្នកណាខ្លះដែលធ្វើឲ្យពូចេះតែនឹកឃើញ ចេះតែភ័យខ្លាចគេចាប់?

ហ៊ុយ បាទ! ពេលគេចាប់ហើយយើងដឹង គេប្រាប់អស់។ ពេលប្រជុំ តាឌុច ហៅប្រជុំទាំងអស់គ្នា គេយកឈ្មោះដូចជា ស្វួន ប្រធានកងវរយពួកខ្ញុំ គេយកឯកសារណឹងមកនិយាយថានៅក្នុងកន្លែងយើងមានឈ្មោះណាខ្លះដែលគេត្រូវឆ្លើយដាក់។ ស្វួនទាក់ទង ហៅយើងអប់រំណែនាំយ៉ាងម៉េចខ្លះ។ ម្នាក់ៗចេះតែភ័យចេះតែព្រួយ ប៉ុន្តែគ្មានអ្នកណាដឹងថាយ៉ាងម៉េចទេ។ អារម្មណ៍ចេះតែភ័យចេះតែព្រួយចឹង នឹកឃើញថាជៀសមិនរួចពីឌុច ចាប់ដាក់គុក។

វណ្ណៈ ខ្ញុំចង់ឲ្យពូលើកពីឈ្មោះអ្នកណាខ្លះដែលបានចាប់ខ្លួន ហើយធ្វើឲ្យពូមានការភ័យខ្លាចគេឆ្លើយដាក់?

ហ៊ុយ ចាប់ពី៧០៣ដូចជា តាប៉ាំង គាត់ជាប្រធានកងពល៧០៣ ម្នាក់ទៀតតានួន, ចែម ស្វួន, តាជូ, តាប៉ូច គ្នាច្រើន ដូចជា គី ជន នេះអីសុទ្ធតែជាមនុស្សស្និតស្នាលជាមួយគ្នា ចឹងអារម្មណ៍ចេះតែភ័យ ព្រោះគេលើកបន្ទុបបានតែ១ភ្លែតៗ ហើយគេចាប់បន្តគ្នា។

វណ្ណៈ ប៉ាំង ជាប្រធានកងពល ឬជាស្ថិតនៅក្នុងលំដាប់វរសេនាធំ?

ហ៊ុយ ពីមុនវរសេនាធំ ហើយក្រោមមកជាជំនួយការកងពល ។ ពេលគេចាប់យកទៅ ខ្ញុំបានលួចសួរតាបាំង ដឹងចម្លើយតាបាំងឆ្លើយដាក់តាហ៊ា ខ្ញុំយកទៅប្រាប់តាហ៊ា ខ្លាចតាឌុចចាប់ ព្រោះកាលណាតាឌុចចាប់តាហ៊ា គឺពួកតាឌុចត្រូវចាប់ពួកខ្ញុំទាំងអស់ទៀត ព្រោះចម្លើយពីតាបាំងឆ្លើយដាក់អ្នកនៅធ្វើការមន្ទីរស-២១ ។ បើចឹងគេតាមចាប់ទៀត ។

វណ្ណៈ ពូមានទំនាក់ទំនងអីជាមួយហ៊ា បានជាពូភ័យខ្លាចពេលចាប់ហ៊ា គេមកចាប់ពូដែរ?

ហ៊ុយ ព្រោះតាហ៊ាពីងផ្អែកខាងពួក៧០៣ទាំងអស់ វាមួយបក្ខមួយពួកម្នាក់ ។ ពួកតាឌុច គេមានមួយបក្ខមួយពួកគេខាងណោះទៀត កាន់ជើងមួយពយកម្នាក់ ។ ដល់ចឹងវាចេះតែព្រួយបារម្មណ៍ ។

វណ្ណៈ យ៉ាងម៉េចបានជាពូដឹងថាបាំងឆ្លើយដាក់ហ៊ា?

ហ៊ុយ ខ្ញុំសួរគាត់ សួថា ហីតាឯងមានរឿងអីបានគេចាប់តាឯងម៉ោ? គេឆ្លើយដាក់អញ ឥឡូវអញឆ្លើយដាក់តាហ៊ាដែរ ។ បានខ្ញុំទៅប្រាប់តាហ៊ាថា បង១! បងឯងប្រយ័ត្ន តាបាំងឆ្លើយដាក់បងឯងហើយ ។ យើងប្រាប់គាត់ឲ្យគាត់ដឹងខ្លួន ខ្លាចគេចាប់ ។ គាត់ដឹងចឹង គាត់ទៅប្រាប់តាបាំងកុំឲ្យឆ្លើយដាក់ឈ្មោះគាត់ ។

វណ្ណៈ ប៉ុន្តែនៅក្នុងចម្លើយមានឈ្មោះហ៊ាដែរ?

ហ៊ុយ អត់មានទេ ព្រោះហ៊ាទៅប្រាប់តាបាំងកុំឲ្យឆ្លើយដាក់ ។

វណ្ណៈ ពេលដែលខ្ញុំសួរពូពីខែមុន ពូថា ពូធ្លាប់ទទួលបញ្ជាពីឌុចឲ្យទៅវាយសម្លាប់អ្នកទោសនៅជើងឯក ។ ខ្ញុំចង់សួរថាពេលដែលពូវាយទៅលើអ្នកទោសក្នុងកាលៈទេសៈណឹង ក្នុងអារម្មណ៍ពូយ៉ាងម៉េចដែរ?

ហ៊ុយ ចុះបើគេហៅឲ្យទៅចឹងហើយ ។ ខ្ញុំនៅកន្លែងកត់ឈ្មោះ ពេលបញ្ជូនទៅម្តង១ ខ្ញុំកត់តែឈ្មោះទេ ហើយពួកគេមួយក្រុមនៅនោះជាអ្នកសម្លាប់ ។ ពេលតាហ៊ាទៅ តាហ៊ាហៅខ្ញុំវៃ ។ ហៅខ្ញុំមកកន្លែងសម្លាប់ណឹង ខ្ញុំខ្លាចគេបន្ទំវៃខ្ញុំដែរ ។ ដល់ហើយគាត់សួរខ្ញុំ ហ៊ុយអ្ហែងហ៊ានវៃមនុស្សដែរ អ្ហែងដាច់ខាតអត់! ។ ចុះយើងមានរឿងអីយើងមិននិយាយថាយើងដាច់ខាតបើយើងមិនដាច់ខាតគេថាយើងខ្លាំងដែរ ចឹងខ្ញុំទាញដែកពីគេវៃ ហើយខ្ញុំបោះដែកចោលចេញម៉ោ ។

វណ្ណៈ ចុះឌុច?

ហ៊ុយ ឌុច ក៏ចឹង។ ធ្លាប់សួរខ្ញុំចឹងដែរ។

វណ្ណៈ តាមពូនិយាយប្រាប់ខ្ញុំថា ពូធ្លាប់វៃមនុស្សអស់៤,៥នាក់។ នៅក្នុងការសម្ភាសន៍ជាមួយអ្នកការសែតបរទេសពូថារហូតទៅដល់២,៣០០នាក់។ ពូគិតថាយ៉ាងម៉េចដែរ?

ហ៊ុយ គ្មានទេ ខ្ញុំគ្មានតួនាទីអីទៅវាយគេទេ។ សួរតាឌុចមើលថាតើមានចាត់តាំងមួយក្រុមនៅណឹងដែរ មានតែពួកណឹងទេ ជីករណ្តៅហើយនិងសម្លាប់គឺមានតែពួកណឹង។

វណ្ណៈ ចុះបើតាមដែលពូធ្វើដោយខ្លួនពូ ពូយល់ថាពូធ្លាប់សម្លាប់អ្នកទោសប្រហែលជាប៉ុន្មាននាក់ដែរ?

ហ៊ុយ តែ៤,៥នាក់ណឹង។ ប៉ុន្តែខ្ញុំមិនបានសម្លាប់ផ្ទាល់ទេ គ្រាន់តែបានវៃ ហើយបោះដែកឲ្យគេនៅណឹងទៅ ព្រោះខ្ញុំមានតួនាទីត្រឹមតែកត់ឈ្មោះយកមកឲ្យបងធំ។

វណ្ណៈ ពូកត់ឈ្មោះរបៀបម៉េច?

ហ៊ុយ កត់ឈ្មោះគេដូចថាគេឈ្មោះអី ម្នាក់ទៀតឈ្មោះអី..កត់ឲ្យគ្រាប់ចំនួនដែលយើងបញ្ជូនទៅហើយយកមកឲ្យគេវិញ ខ្លាចបាត់ឈ្មោះ។

វណ្ណៈ របៀបសម្លាប់នៅជើងឯកគេធ្វើយ៉ាងម៉េចពូ?

ហ៊ុយ នៅជើងឯក ដូចថាមនុស្សដែលយកទៅគេដាក់ខ្នោះ ដាក់ដៃមកក្រោយ ហើយចងមុខ។ ពេលទៅដល់កន្លែងណឹងដាក់ចុះពីលើឡានបញ្ចូលទៅក្នុងផ្ទះហើយចាប់ផ្តើមឲ្យ ពួកអ្នកយកទៅបណ្តើរចេញម្តងមួយៗ ហើយខ្ញុំអ្នកកត់ឈ្មោះ ហើយឲ្យគេយកទៅៗ។ ពួកអ្នកនៅណោះគឺម៉ាក្រុមគេសម្រាប់ចាំតែវៃមនុស្ស។ ពេលវៃមនុស្ស គេយកមនុស្សទៅដល់ដាក់ឲ្យអង្គុយចោងហោង លត់ជង្គង់ហើយគេវៃ។ គេវៃហើយ គេអារ-ក ហើយបានដោះខ្នោះដៃ យកអ្នកទោសបោះទៅក្នុងរណ្តៅ។

វណ្ណៈ ខ្ញុំចង់សួរពីការវិនិច្ឆ័យរបស់ពួកមេដឹកនាំខ្មែរក្រហម របស់ឌុច, សុន សេន, ប៉ុល ពត, នួន ជា, ការវិនិច្ឆ័យទៅលើអ្នកទោសចុងក្រោយ គឺអ្នកទោសភាគច្រើនត្រូវតែយកទៅសម្លាប់ ទោះបីខុសតិចក្តីច្រើនក្តី ដោយចោទថាជា សេ.អ៊ី.អា។ ចឹងបន្ទាប់ពីសួរចម្លើយហើយគឺយកទៅសម្លាប់។ ប៉ុន្តែថ្មីនេះសភាបានអនុម័តច្បាប់ស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយច្បាប់ណឹងព្រះករុណាសម្តេចសីហនុបានឡាយព្រះហស្ថលេខាថា ឲ្យមានការបង្កើតតុលាការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមទាំងអស់ណឹង។ ប៉ុន្តែនៅមាត្រា

មួយនោះនិយាយពីការកាត់ទោសប្រហារជីវិត ហើយមានមតិជំទាស់មិនត្រូវដាក់ថា កាត់ទោសប្រហារជីវិតទេ អាចដាក់ត្រឹមតែជាប់គុកអស់មួយជីវិត។ ចឹងវាផ្ទុយគ្នា ពួកណឹងឲ្យតែចាប់អ្នកទោសបាន គឺយកទៅសម្លាប់។ ប្រសិនបើមានការកាត់ក្តីចំពោះមេដឹកនាំខ្មែរក្រហម គឺគេគ្រាន់តែយកអ្នកទាំងអស់ណឹងដាក់គុកអស់មួយជីវិតទេ គឺមិនយកទៅសម្លាប់ទេ។ ចឹងមានន័យថាពួកណឹងអត់ត្រូវគេយកទៅសម្លាប់ទេ ស្លាប់ពេលណាពេលណឹងទៅ។ ពូយល់ថាយុត្តិធម៌ដែរ?

ហ៊ុយ ខ្ញុំមិនដឹងដែរនៅលើច្បាប់ ទោះបីខ្ញុំនិយាយក៏មិនថាយ៉ាងម៉េចដែរ ព្រោះខ្ញុំមិនមែនជាអ្នកច្បាប់ផង។

វណ្ណៈ សម្រាប់ពូយល់ឃើញវិញ ដែលពួកណឹងបានបញ្ជាឲ្យមានការសម្លាប់មនុស្ស ហើយបែរជាច្បាប់មិនបានយកអ្នកណឹងទៅសម្លាប់វិញ តើយ៉ាងម៉េច?

ហ៊ុយ ខ្ញុំអត់ដឹង។

វណ្ណៈ ប៉ុន្តែបើធ្វើចឹងយុត្តិធម៌ទេសម្រាប់ជនរងគ្រោះ?

ហ៊ុយ ទេខ្ញុំមិនដឹងដែរ ព្រោះខ្ញុំទីពឹងតែទៅលើច្បាប់ បើច្បាប់ធ្វើយ៉ាងម៉េចក៏ធ្វើទៅខ្ញុំអត់ដឹងទេ។

វណ្ណៈ ប៉ុន្តែបើតាមពូយល់ឃើញ ពួកអស់ណឹងគួរតែយកទៅឃុំឃាំងអស់មួយជីវិតឬក៏គួរតែយកទៅសម្លាប់ដូចអ្វីដែលពួកណឹងបានធ្វើ?

ហ៊ុយ ទោះជាខ្ញុំនិយាយក៏មិនដឹងថាយ៉ាងម៉េច។

វណ្ណៈ ចុះប្រសិនបើមានតុលាការ ហើយតុលាការចង់ហៅពូឲ្យទៅនិយាយ តើពូអាចទៅនិយាយប្រាប់គេបានដែរ?

ហ៊ុយ បាទ! បាន ខ្ញុំនឹងនិយាយបាន។

វណ្ណៈ ពូនឹងចង់និយាយប្រាប់ពីអ្វីខ្លះ បើសិនជាពូមានឪកាសនិយាយ?

ហ៊ុយ ឲ្យតែគេសួរខ្ញុំយ៉ាងម៉េច ខ្ញុំនិយាយចឹង។

វណ្ណៈ ប្រសិនបើពូយល់ឃើញថាឲ្យមានយុត្តិធម៌សម្រាប់ជនរងគ្រោះ តើគួរមានតុលាការរបៀបម៉េចដែរពូ?

ហ៊ុយ ខ្ញុំអត់ចេះទេ។

វណ្ណៈ សម្រាប់អ្នកស្រុកសព្វថ្ងៃ ក៏ដូចជាប្រពន្ធកូនពូ គេយល់ឃើញ គេស្អប់ គេស្រឡាញ់ចំពោះពូយ៉ាងម៉េចដែរ?

ហ៊ុយ ខ្ញុំមិនដែលមានរឿងរ៉ាវអីទេ ខ្ញុំនិយាយត្រង់ៗ តាំងពីដឹងក្តីពីតូចម៉ោខ្ញុំមិនដែលទាស់ជាមួយអ្នកណាទេ ហើយសព្វថ្ងៃនេះក៏ចឹងដែរ ។ បើនិយាយពីរឿងស៊ីដឹកវិញ ខ្លាចតែខ្ញុំមិនដឹករបស់គេ ។

វណ្ណៈ ពូមានដែលសោកស្តាយពីអតីតកាលរបស់ពូដែរ?

ហ៊ុយ ដូចខ្ញុំជម្រាបចឹងថា ខ្ញុំចង់ល្អណាស់ ខ្ញុំមិនចង់អាក្រក់ទេ ។ ថាលោកណាក៏ដោយ បេះដល់ថ្នាក់ណាក៏ដោយ ឲ្យតែមកនៅកន្លែងណឹង(ស-២១) គេឲ្យធ្វើអី គឺធ្វើណឹង ។ បើមិនធ្វើគឺអ្នកឯងត្រូវតែស្លាប់ ។ ដូចខ្ញុំជម្រាបចឹង អ្នកការពារប្រមាណ២០០នាក់ ស្លាប់អស់នៅមិនដល់១០០នាក់ផង ស្លាប់បន្តបន្ទុយគ្នា ។

វណ្ណៈ អ្នកណាខ្លះដែលបញ្ជាពូតាំងពីលើបន្តបន្ទាប់មក?

ហ៊ុយ បន្ទាប់ពីខ្ញុំ តាហ៊ិ ។ បន្ទាប់ពីតាហ៊ិ គឺឌុច ។

វណ្ណៈ ប៉ុន្តែមានអ្នកណាផ្សេងទៀតទេដែលអាចមានលទ្ធភាពបញ្ជាពូឲ្យធ្វើអីបានទៀត?

ហ៊ុយ អត់មានទេ មានតែផលប្រធានកងវរយនៅណឹង ។

វណ្ណៈ ចុះចាន់, ប៊ុន?

ហ៊ុយ ណឹងគេផ្នែកខាងឯកសារ ។

វណ្ណៈ ចុះហ៊ុយស្រែ?

ហ៊ុយ ហ៊ុយស្រែក៏ជាអ្នកអាចបញ្ជាខ្ញុំបានដែរ ។

វណ្ណៈ បញ្ជារបៀបម៉េចដែរពូ?

ហ៊ុយ ចុះគាត់សមាជិកមន្ទីរណឹង គាត់ចង់ឲ្យខ្ញុំធ្វើអីក៏បានដែរ ។

វណ្ណៈ ហ៊ុយធ្លាប់បញ្ជាពូឲ្យធ្វើអីដែរ?

ហ៊ុយ ពេលដែលខ្ញុំទៅធ្វើស្រែជាមួយគាត់ គាត់បានបញ្ជាខ្ញុំឲ្យដឹកនាំកម្លាំងធ្វើស្រែ ។

វណ្ណៈ ខ្ញុំចង់បញ្ជាក់ពីតួនាទីចុងក្រោយរបស់ពូនៅស-២១?

ហ៊ុយ ចុងក្រោយធ្វើស្រូវ ។ កាលមុនតាហ៊ិបានចាត់តាំងខ្ញុំឲ្យធ្វើអនុប្រធានកងវរយបណ្តោះការពារអាសន្ន ។

វណ្ណៈ ហ៊ី អ្នកចាត់តាំង?

ហ៊ុយ បាទ ។

វណ្ណៈ បញ្ហាពីឌុចម៉ោដែរឬក៏យ៉ាំងម៉េច?

ហ៊ុយ ខ្ញុំមិនដឹង ។ តាហ៊ី គាត់អនុប្រធានមន្ទីរស-២១ ហើយគាត់ត្រួតពួកខ្ញុំខាងការពារទៀត ។

វណ្ណៈ សម្រាប់ពូផ្ទាល់ ពូយល់ថាគួរមានតុលាការដែរ?

ហ៊ុយ អត់ដឹងទេ ។

វណ្ណៈ ចុះបើមានពូថាយ៉ាំងម៉េចដែរ?

ហ៊ុយ អត់មានថាម៉េចទេ បើគេចង់ដឹងខ្ញុំអាចទៅនិយាយបាន ។

វណ្ណៈ ពូគិតថានឹងនិយាយប្រាប់កូនចៅរបស់ពូពីរឿងខ្មែរក្រហមតទៅទៀតដែរ នៅពេលដែលវាដឹងក្តី?

ហ៊ុយ ខ្ញុំប្រាប់ទាំងអស់ ធំឡើងឲ្យវាដឹង ។ ចុះរឿងចឹងលាក់ធ្វើអី ។

វណ្ណៈ ពូមានដែលជួបបញ្ហាអ្នកស្រុកចំអកឡកឡឺយដែរ?

ហ៊ុយ អត់មានដែលនិយាយទេ ។

វណ្ណៈ ចុះបើសិនគេនិយាយ ពូខឹងគេទេ?

ហ៊ុយ ខ្ញុំអត់មានខឹងទេ ព្រោះខ្ញុំនិយាយរឿងរ៉ាវប្រាប់គេអស់ហើយ ។ គេខឹងខ្ញុំម៉េចកើត បើបងប្អូនគេគ្រប់គ្នាគេថាចឹងដែរ អ្នកណាចង់ទៅធ្វើទ័ពជិនាន់ណឹង អត់មានចង់ទេ មកវិញពិការដៃពិការជើង វេទនាណាស់ជំនាន់ណឹង ។ ដល់ចឹងមានអ្នកណានិយាយកើត បើវាធម្មតាសង្គមណឹងនាំវានិយាយចឹងហើយ ។ ខ្ញុំក៏ប្រាប់គេអីចឹង ខ្ញុំសុំគេចេញ ។ កាលមុនទៅនៅណឹងគេសម្អុតខ្ញុំថាមានរឿងមានរ៉ាវ ថាឲ្យខ្ញុំទៅទ័ពអាម៉ារីន តែឌុបខ្ញុំយកមកចូលនៅណឹង (ស-២១) ។ ដល់ហើយសួរខ្ញុំថា អ្អែងដឹងថាមានរឿងអីទេ? ដល់ចឹងបេះតែគិត ។ កាលខ្ញុំនៅទ័ពខ្ញុំធ្លាប់រត់គេចទៅផ្ទះមិនដឹងជាប៉ុន្មានដងទេ ប្រធានភូមិបេះតែស្ញូ ។ តែកាលណឹងបើកុំតែមកវិញ ក៏កងវរយគេទៅចាប់ពីផ្ទះយកមកវិញដែរ ព្រោះខ្ញុំទៅផ្ទះបាន៥ថ្ងៃ ខ្ញុំគេចចេញពីទ័ពព្រោះខ្លាចងាប់ ។ ប៉ុន្តែបើនៅភូមិក៏មិនរស់ដែរ ព្រោះគេតឹងទៅៗ ។ កងវរយថា "ហី អ្អែងប្រញាប់មកម្ល៉េះ?" ។ ពេទ្យរាយការណ៍ថា ខ្ញុំដើរសេរី អត់មានសុំច្បាប់គេ ។ នឹកឃើញទាំងអស់ណឹងបានគិតថា ខ្លួនឯងបែបមានរឿងអីហើយ បានគេហៅ

ចូលទៅគុកទួលស្លែង ។ ខ្ញុំថា "ចុះក្រែងបងឯងឲ្យខ្ញុំទៅទ័ពអាម៉ារីន?" ។ ចុះខ្ញុំខ្លាចទឹកនោះ ខ្ញុំគ្មានចង់ទៅទ័ពអាម៉ារីនអី ។ "យី! ទៅទ័ពអាម៉ារីនអី អ្ហែងមានរឿង" ។ "ខ្ញុំអត់ដឹងមានរឿងអីទេបង" ។ "អ្ហែង! ទៅដល់គន់តែដឹងទេ" ។ សុទ្ធតែជាការសម្ងាត់របស់គេទាំងអស់ ដូច្នេះខ្ញុំជ្រើសរើសយ៉ាងម៉េច ។ ហ៊ី កន្តុញ ជាអ្នកឌុបខ្ញុំយកទៅដល់ទួលស្លែងតែម្តង ។

វណ្ណៈ ឌុបដាក់ផ្សារថ្មី ឬដាក់នៅទួលស្លែង?

ហ៊ុយ ដាក់នៅទួលស្លែង ។

វណ្ណៈ ហ៊ី ដែលមានឱកាសចេញចូលទួលស្លែងទៀត បន្ទាប់ពីឌុបពូយកទៅ?

ហ៊ុយ អត់ទេ ។

វណ្ណៈ ពួកណឹងមានតួនាទីចូលទួលស្លែងបានទេ?

ហ៊ុយ អត់ទេ ។

វណ្ណៈ ប៉ុន្តែបើចាប់មនុស្សបាន អាចចូលទៅទេ?

ហ៊ុយ ចូលបានតែខាងក្រៅ ។

វណ្ណៈ ខ្ញុំអរគុណហើយពូ ។

ហ៊ុយ បាទ

## ចប់វគ្គទី១

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីការសម្លាប់នៅមន្ទីរស-២១ ដែលអ្នកធ្វើការនៅស-២១ត្រូវបាន ហ៊ី និង ឌុច បញ្ជាឲ្យចាប់ខ្លួនយកទៅសម្លាប់វិញ បានកើតឡើងនៅឆ្នាំណាដែរពូ?

ហ៊ុយ បើគិតទៅតាំងពីឆ្នាំ១៩៧៦មក ។

វណ្ណៈ ពូដឹងរបៀបម៉េច?

ហ៊ុយ ខ្ញុំដឹងត្រង់ថា ខ្ញុំឃើញពួកកងឈ្មួយចាស់ៗដែលគេទៅនៅមុនពួកខ្ញុំ គេចេញចាប់មនុស្សជាមួយ ហ៊ី នៅតាមកងពល ។

វណ្ណៈ ចឹងមន្ទីរស-២១ចេញទៅចាប់ផ្ទាល់?

ហ៊ុយ ចេញទៅចាប់តាមរយៈកងពល ។ អាណឹងយើងទៅសហការណ៍ជាមួយកងពល ។ ដូចថាខ្ញុំចេញទៅចាប់នៅកងពលណាមួយ គេចាប់មកឲ្យហើយយើងចាំទទួលយកមក ។

វណ្ណៈ ចុះមានករណីកងពលណាមួយចាប់យកមកឲ្យដល់របងស-២១ដែរ?

ហ៊ុយ ជួនកាលគេចាប់យកមកខ្លួនគេ បញ្ជូនយកមកឲ្យដល់កន្លែងណីងហ្នឹង ស-២១ ។

វណ្ណៈ កងវរសេនាតូចពិសេស៧០៤ របស់កងពលលេខ៧០៣ មានដែលចាប់មនុស្សមកឲ្យ ស-២១ដែរទេ?

ហ៊ុយ ធ្លាប់ចាប់ ។

វណ្ណៈ យ៉ាងម៉េចបានជាពូហ៊ានថា ចាប់?

ហ៊ុយ ព្រោះកងវរណឹង ខ្ញុំធ្លាប់នៅជាមួយ ធ្លាប់ស្គាល់គ្នា ។

វណ្ណៈ ពូមានស្គាល់អ្នកណាម្នាក់ដែរ?

ហ៊ុយ ខ្ញុំចាំ តែមិនស្គាល់ឈ្មោះ ។ តែក្រោយមកអ្នកចាប់គេណឹង គេចាប់យកមកដាក់ស-២១ ណឹងវិញ ដូចតែគ្នា ។

វណ្ណៈ ខ្ញុំចង់បញ្ជាក់ពូម្តងទៀត ។ ពេលដែល៧០៤មនុស្ស យកមកឲ្យដល់កន្លែងស-២១ ឬក៏ពូទៅទទួលនៅកន្លែងណាមួយ?

ហ៊ុយ ជួនកាលទៅទទួល ជួនកាលទៅយកដល់កន្លែងគេ ដូចនៅជិតផ្សារថ្មី ជួនកាលនៅតាខ្មៅ ព្រោះកន្លែងអត់ទៀត ។

វណ្ណៈ ពេលពូទៅយកអ្នកទោស មានយកអីខ្លះទៅជាមួយ?

ហ៊ុយ មានយកខ្នោះទៅជាមួយគេ ។

វណ្ណៈ មានការផ្ទៀងផ្ទាត់ឈ្មោះអីយ៉ាងម៉េចដែរ?

ហ៊ុយ ព្រោះគេប្រាប់មក តាឌុច នេះហើយ ឬក៏ប្រាប់ ហ៊ី ។ គេប្រាប់ ឌុច ។ ឌុច ប្រាប់តាហ៊ី ឲ្យពួកខ្ញុំទៅយក ។

វណ្ណៈ អ្នកទៅចាប់ជាមួយពូមានអ្នកណាខ្លះ?

ហ៊ុយ មាន តាហ៊ី ខ្ញុំ, ប៊ូ និងយុទ្ធជននៅជាមួយអ្នកធំៗដែលអាចហៅទៅចាប់បាន ។

វណ្ណៈ ប៊ូ ធ្វើអីដែរ?

ហ៊ុយ ប៊ូ ជាបញ្ជាការកងការពារ ហើយក្រោយមកដកទៅខាងសួរចម្លើយ ។

វណ្ណៈ ដកនៅឆ្នាំណា?

ហ៊ុយ ឆ្នាំ៧៧ ។ ដំបូង ប៊ូ ចេញទៅចាប់ដែរ ដល់តែក្រោយមក ទៅខាងសួរចម្លើយ ។

វណ្ណៈ ពេលមកនៅស្ទួរចម្លើយ ប៉ុ មានចេញទៅចាប់ទៀតដែរ?

ហ៊ុយ ជួនកាលគេហៅទៅជាមួយ ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីឈ្មោះ ចឹក ដែលចងករសម្លាប់ខ្លួននោះដោយសាររឿងអី?

ហ៊ុយ ចឹក នៅក្រុមជាមួយខ្ញុំគេកសាង គេណែនាំរាល់ថ្ងៃកុំឲ្យមានចិត្តខ្លាំង ។ តែអានេះចរិតគ្នាចឹងទៅហើយ ។ ចឹក ណឹងត្រូវធ្វើអីក៏ធ្វើ បើមិនធ្វើទេ ពុតធ្វើជាឈឺក្បាល ទៅដេក ។ ដល់ហើយគេណែនាំឲ្យកែប្រែ ។ ចុះប្រជុំម្តងគេរាយការណ៍ម្តង១ ដល់ចឹងរាយការណ៍ញឹកញាប់ពេក តាហ៊ំ ហៅខ្ញុំសួរ ។ "ហ៊ុយ អ្អែងយ៉ាំងម៉េចរឿង ចឹក?" ។ ខ្ញុំថា"បងអ្អើយ! ខ្ញុំមិនទាន់បានកសាងណែនាំអស់សមត្ថភាខ្ញុំផង ទុកខ្ញុំណែនាំសិន" ។ គាត់ថា"ទុកក៏ទុកទៅ តែបើមិនកែប្រែ ប្រាប់ ។ ត្រូវដក ដក ត្រូវទុក ទុក" ។ ខ្ញុំថា "បាទ" ។ ដល់ហើយទើបតែនិយាយថ្មើណឹង ស្អែកឡើងមកប្រាប់ខ្ញុំ "បង១! ខ្ញុំទៅរកប្រូតត្រកួនឲ្យទន្សាយ" ។ ខ្ញុំថា "តែទៅ ចឹកឯងស្រូតមកវិញ" ។ ដល់ទៅទល់ម៉ោង១២គេមកហូបបាយអស់រលីង "ចុះបាត់គាត់នេះអីក៏យូរម្លេះ?" ។ ដល់ហើយខ្ញុំចាប់ភ័យខ្លួនឯង "ទេ!គាត់នេះយ៉ាំងម៉េច១គេចាប់អញហើយ" ។ ដូចគេថាមែន ខ្ញុំក៏ដើររក គេក៏ដើររកពេញទឹកពេញដី ។ ស្រាប់តែទៅឃើញនៅក្នុងផ្ទះឈើប្រក់ក្បឿងនៅក្នុងទឹក នៅអូរខាងត្បូងទួលស្លែង ។ គាត់ចងកនៅណឹង ។ ដល់ម៉ោវិញខ្ញុំរាយការណ៍ប្រាប់ ហ៊ំ ។ តាហ៊ំថា "ម៉េច ហ៊ុយឯង! អត់ជឿ!" ។ ខ្ញុំថា"ជឿបង ។ បើខ្ញុំខ្ញុំមិនទាន់បានកសាង បើខ្ញុំដឹងថាចិត្តគាត់ចឹង ក៏ខ្ញុំអត់ទុកដែរ ឲ្យបងឯងដកទៅណាក៏យកចុះ តែខ្ញុំមិនបានកសាងផង ហើយពួកណឹងចេះតែកសាងបំបាក់មុខបំបាក់មាត់គ្នា ។ បើកសាងស្រួលបួលមែនអី មនុស្សកែប្រែហើយ ព្រោះមនុស្សចិត្តខ្លាំងចឹងវាពិបាកនៅ ហើយមនុស្សចិត្តខ្លាំង ចឹងចងកខ្លួនឯងស្លាប់តែម្តង" ។ "ចឹងឥឡូវយ៉ាំងម៉េច ហ៊ុយ ឯងបើស្លាប់ហើយ គិតយ៉ាំងម៉េច? ចឹងមានតែ ហ៊ុយ ឯងកាន់ជើងខ្លាំង" ។ ខ្ញុំថា "ខ្ញុំអត់មានកាន់ជើងទេបង តែខ្ញុំអាណិតគ្នា មុននឹងយ៉ាំងម៉េច១កសាងឲ្យអស់ចិត្តសិនឲ្យអស់សមត្ថភាព" ។ ដល់ហើយគាត់ដើរមកមើល "ចឹងអ្អែង អញថាឲ្យដកអត់ដកទេ អ្អែងចូលគុកខ្លួនឯងបានសម ជំនួនវាទៅ" ។ ខ្ញុំថា "មិនចឹងទេបង" ។ ហើយបានសែងយកមកកប់ក្បែរផ្លូវលំណឹង នៅជិតកន្លែងចងករ ។

វណ្ណៈ ចឹក មានតួនាទីអីដែរ?

ហ៊ុយ ជាយុទ្ធជន ជាកូនក្រុមរបស់ខ្ញុំ ។

វណ្ណៈ ការកសាងមនុស្សម្នាក់ៗ គេធ្វើយ៉ាងម៉េច?

ហ៊ុយ គេដាក់ខ្លួននៅក្នុងអង្គប្រជុំ ដូចថាមេក្រុមប្រាប់ថា មួយល្ងាចប្រជុំម្តងៗ រាយការណ៍ ។ មេក្រុមគេលើកឡើងឲ្យប្រជុំរិះគន់-ស្វ័យរិះគន់គ្នា អ្នកណាខុសអីៗក្នុងមួយថ្ងៃៗ ។ គ្មានអ្នកណាអត់ខុសទេ សុទ្ធតែខុសទាំងអស់ ។ តែមិនដាក់ថាមិនខុស គឺមិនបាន ។ យើងនិយាយសារភាពខ្លួនឯងថា យើងខុស ។ ចុះបើគេថា បើយើងអត់ថាខុស គឺមិនបាន ព្រោះម្នាក់ៗគ្មានអ្នកណាដែលគ្មានកំហុសទេ គ្រាន់តែខុសតិចខុសច្រើន ។

វណ្ណៈ មានអ្នកណាខ្លះដែលចូលរួមកសាង?

ហ៊ុយ ម៉ាក្រុមគ្នា៦,៧នាក់ណឹង ។ ដល់ហើយយើងរាយការណ៍ទៅលើៗទៀត ទៅហ៎ ។ ហើយបើអត់មានតែមួយល្ងាច គឺហៅទៅសួរតែម្តង ។

វណ្ណៈ ចុះពេលដែលពូចូលគុកទួលស្លែងនៅឆ្នាំណាដែរពូ?

ហ៊ុយ នៅឆ្នាំ៧៦ ។

វណ្ណៈ កាលណឹងយ៉ាងម៉េចបានជាគេឲ្យពូទៅយាម?

ហ៊ុយ គេដកមួយកងវរចំនួនមួយក្រុមៗយកទៅយាមស្លែង ។ កាលណឹងគ្នាច្រើន ។

វណ្ណៈ ពេលនៅពូទៅស-២១ហើយឬនៅ?

ហ៊ុយ ខ្ញុំនៅ៧០៣ ។

វណ្ណៈ ចឹងចូលគុក ពេលនៅក្នុង៧០៣ ឬនៅស-២១?

ហ៊ុយ នៅ៧០៣ ។

វណ្ណៈ ខាងណាដែលទៅដកឲ្យទៅយាមនៅស្លែង?

ហ៊ុយ កងពល និង កងវរៈ ។

វណ្ណៈ នៅស្លែងគេមានធ្វើអីដែរ?

ហ៊ុយ ដូចថាគេហៅទៅរៀនសូត្រពីថ្ងៃជ័យជំនះ១៧មេសា ។

វណ្ណៈ ពូទៅរៀនសូត្រ ឬទៅការពារ?

ហ៊ុយ ទៅការពារ?

វណ្ណៈ អ្នកណាខ្លះដែលទៅរៀនសូត្រ?

ហ៊ុយ ទៅទាំងអស់គ្នាជាយោធា ។

វណ្ណៈ ចុះស៊ីវិល?

ហ៊ុយ អត់មានទេ ។

វណ្ណៈ ពូមានចាំថា កម្មាភិបាលយោធាធំៗដែលចូលរួមក្នុងវគ្គណឹងមានអ្នកណាខ្លះដែរ?

ហ៊ុយ មិនដឹងដែរ កាលណឹងខ្ញុំអត់ស្គាល់ផង ។

វណ្ណៈ ពូយាមនៅទីតាំងណាដែរ?

ហ៊ុយ ខ្ញុំយាមនៅខាងក្រៅផ្នែកខាងជើង ។

វណ្ណៈ ហើយអ្នកណាជាប្រធានពូ?

ហ៊ុយ តាហ៊ីខាក់ និង តាហ៊ីកន្តុញ និងពួក បងនួន ។ បងនួន គាត់នៅវរសេនាតូច៧០៤ ។

ទ្រី ពេលណឹងអ្នកណាដែលនិយាយនៅក្នុងអង្គមិទ្ទិងណឹង?

ហ៊ុយ មានតែ ប៉ុល ពត ណឹង ។

ទ្រី គេហៅពិធីបុណ្យអីដែរ?

ហ៊ុយ ១៧ មេសា ។

ទ្រ អាណឹងធ្វើនៅលើកទី១?

ហ៊ុយ បាទ! ធ្វើនៅស្តាត ធ្វើតែមួយថ្ងៃទេ តែខ្ញុំយាមតាំងពីយប់ ។

ទ្រី ពូគ្រាន់តែយាម ឬទៅខាងក្នុងចូលរួមដែរ?

ហ៊ុយ ខ្ញុំយាមនៅខាងក្រៅ ។

ទ្រី អ្នកណាដែលចូលរួមខ្លះ?

ហ៊ុយ មានតែកងវរៈអីណឹងដែលចូរួម ។

ទ្រី គេមាននិយាយអីខ្លះទាក់ទង១៧មេសា?

ហ៊ុយ គេនិយាយតាមមេក្រូថា ថ្ងៃ១៧មេសា ជាថ្ងៃជ័យជំនះរបស់បដិវត្តន៍ ។

ទ្រី ជាសម្តីរបស់អ្នកណា?

ហ៊ុយ ជាសម្តីរបស់ ប៉ុល ពត តែខ្ញុំមានទៅស្គាល់អី ប៉ុល ពត ខ្ញុំនៅតែក្រៅ ។

ទ្រី មានភ្ញៀវបរទេសចូលរួមដែរ?

ហ៊ុយ អត់មានទេ ។

ទ្រី គេធ្វើពីពេលម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

ហ៊ុយ តាំងពីម៉ោង៧ព្រឹកដល់ម៉ោង១១ ប៉ុន្តែពួកយាមអត់ចេញទេ ផ្លាស់គ្នាហូត ។ ពួកយាមដូចថា ម៉ាកងវរទ្ធមួយដុំ ខាងបូព៌ាមួយដុំ ខាងឧត្តរមួយដុំ ដាក់ឆ្លាស់គ្នាហូត ។

ទ្រី ពូនៅក្នុងវេនទីប៉ុន្មាន?

ហ៊ុយ ទេ ខ្ញុំមិនដឹងដែរទេកាលណឹង ។ ហើយល្ងាចម៉ោង២គេចូលទៀតបន្តដល់ម៉ោង៥ ។

ទ្រី ស្អែកឡើងមានធ្វើទៀតទេ?

ហ៊ុយ ទេកាលណឹងធ្វើតែមួយយប់ មួយថ្ងៃ ។

វណ្ណៈ ប៉ុន្តែកងពលពូនៅកៀកនឹងស្តាត ឬក៏នៅឆ្ងាយពីស្តាត?

ហ៊ុយ នៅខាងក្រៅ ។

វណ្ណៈ ពូមានដឹងថាខាងណាដែលយាមនៅខាងក្នុង?

ហ៊ុយ ទេ កាលណឹងដូចជាពួកខាងឧត្តរ ឬ ខាងបូព៌ាទេ ខ្ញុំមិនដឹងដែរ ព្រោះគេនៅដល់ខាងក្នុងស្តាតទៀតណោះ ហើយពួកខ្ញុំនៅខាងក្រៅស្តាតនេះ ។

វណ្ណៈ ពូមានរែកអេះអីដែរ?

ហ៊ុយ ខ្ញុំអត់មានរែកទេ រែកតែអ្នកនៅយាមខាងក្នុង ។ គេដើរជាជួរមក ប្រុសរែកដោយប្រុស ស្រីរែកដោយស្រី ។

ទ្រី ពេលដែលពូធ្វើ១៧មេសាចប់ គេឲ្យពូទៅណា?

ហ៊ុយ គេឲ្យទៅធ្វើស្រែ នៅខាងក្រោយអគ្គិសនីចាក់អង្រែ ដល់ហើយទៅតាខ្មៅគេហៅព្រែកជ្រៅ ទៅធ្វើនៅនោះយូរដែរ ហើយទៅយាមនៅរដ្ឋករទឹកល្អក់ ។

ទ្រី ចឹងបានន័យពេលដែលឈ្នះឆ្នាំ១៩៧៥ មិនទាន់មានធ្វើថ្ងៃជ័យជំនះ១៧មេសាទេ ដល់ឆ្នាំ៧៦ទើបធ្វើ ។

ហ៊ុយ អត់ទេ ។

វណ្ណៈ ពេលដែលពូយាម ពូមានឮកើតមានព្រឹត្តិការណ៍ចាប់ចងអីយ៉ាងម៉េចដែរ?

ហ៊ុយ អត់ទេ អត់ដឹងទេ ។

វណ្ណៈ ប៉ុន្តែតាមខ្ញុំសម្ភាសន៍ជាមួយខាង៧០៣ដែរថា ពេលប្រជុំណឹងមានខាងឧត្តរបះបោរ ។ ពូយល់ថាយ៉ាងម៉េចដែរ?

ហ៊ុយ	បះបោរ ខ្ញុំឮគេនិយាយថាបះបោរ ។ ខ្ញុំអត់ដឹងដែរ ដល់ពេលចេញមកបានឮគេនិយាយ ។

វណ្ណៈ	រហូតដល់ពេលណាដែលពូដឹង?

ហ៊ុយ	ចេញពីប្រជុំវិញណឹងបានដឹង ។

វណ្ណៈ	អ្នកណាដែលប្រាប់ឲ្យដឹង?

ហ៊ុយ	អ្នកនៅកងជាមួយគ្នាណឹង ។

វណ្ណៈ	ជាប្រធានពូ ឬក៏សមាជិក?

ហ៊ុយ	ពួកគាហ៊ឹ កន្ទុញអីណឹង មានគ្នាច្រើនទៀត ។

វណ្ណៈ	បះបោរជាទ្រង់ទ្រាយឬក៏យ៉ាងម៉េច?

ហ៊ុយ	គ្រាន់តែហៀបនឹងបះបោរ ។

វណ្ណៈ	ដោយសារអីដែរ?

ហ៊ុយ	ខ្ញុំអត់ដឹងដែរ ។

វណ្ណៈ	ហើយដោយសារអីបានជាមានការចាប់ចង?

ហ៊ុយ	ខ្ញុំក៏មិនបានដឹងដែរ ។

វណ្ណៈ	ពូមានដឹងថា ខាងខុត្តរបះបោរនោះ អ្នកណាដែលដឹកនាំធ្វើដែរ?

ហ៊ុយ	អត់ដឹងអីផង គ្រាន់តែឮថា វ៉ិះបាញ់គ្នា ។

វណ្ណៈ	តាមដែលខ្ញុំសម្ភាសន៍ជាមួយ៧០៣ដែរ ថាមានចាប់ខាងខុត្តរជាង១០០នាក់?

ហ៊ុយ	ខ្ញុំអត់ដឹងដែរ តែមានតែចាប់មកមន្ទីរស-២១ អាណឹងមានចាប់ពួកខាងខុត្តរ ។ កាលខ្ញុំនៅ ៧០៣ ខ្ញុំអត់មានដឹងថា មានចាប់ខាងខុត្តរទេ តែពេលខ្ញុំមកនៅស-២១ដឹងឃើញមាន ចាប់មក ។

វណ្ណៈ	ពូដឹងរបៀបម៉េច?

ហ៊ុយ	ដឹង! ព្រោះគេហៅខ្ញុំទៅចាប់ ។

វណ្ណៈ	ពូមានចាំឈ្មោះពួកខុត្តរណាខ្លះដែលពូចាប់ដែរ?

ហ៊ុយ	ខ្ញុំអត់មានចាំទេ ។

វណ្ណៈ	ចុះដូចជា កុយ ធួន ?

ហ៊ុយ	អាណឹងកងវរយគេមុនៗអ្នកទៅចាប់ ។

វណ្ណៈ ពេលចាប់មនុស្សអាចខាងពិសេស៧០៤ចាន់ដែរទេ?

ហ៊ុយ ទាក់ទងដោយសារខាងកងពល៧០៣ សហការជាមួយស-២១ ។

វណ្ណៈ ៧០៣ជាផ្នែកមួយរបស់ស-២១ ឬក៏ដាច់ពីគ្នា?

ហ៊ុយ ៧០៣មិនមែនជាប់នៅជាមួយមន្ទីរស-២១ទេ វាជាកងពលដោយឡែក ប៉ុន្តែកម្មាភិបាល ដូចថា តាឌុច ទៅទាក់ទងជាមួយ៧០៣ឲ្យទៅជួយចាប់ ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយករណីដែលពូបានឃើញដោយផ្ទាល់ តើពូធ្លាប់មានឃើញអ្នកណាម្នាក់នៅ ៧០៤ដែលធ្លាប់ទៅចាប់អ្នកណាម្នាក់មកស-២១នេះ ដែលពូហ៊ានអះអាងថា ពួកខាង ៧០៤ទៅចាប់មនុស្ស?

ហ៊ុយ ចាប់ចឹងមែន បើខ្ញុំមើលឃើញ តែខ្ញុំភ្លេចឈ្មោះហើយ ។ តាហ៊ី កន្ទុញក៏ទៅចាប់ តាហ៊ី នៅស-២១ក៏ទៅចាប់ ហើយបងនួន ក៏ទៅចាប់ ឲ្យតែគេបញ្ជា ។

វណ្ណៈ ចឹងចាប់ហើយបញ្ជូនមកស-២១ ឬក៏មានទុកនៅកន្លែងមន្ទីរអប់រំ៧០៤?

ហ៊ុយ មិនដឹង ។

វណ្ណៈ ប៉ុន្តែពូឃើញបញ្ជូនមកផ្ទាល់ ឬក៏មិនផ្ទាល់ទេ?

ហ៊ុយ យកមកពេលខ្ញុំនៅគឺឃើញផ្ទាល់ តែចាប់មុនៗខ្ញុំមិនដឹងដែរទេ ។

វណ្ណៈ ចឹងចាប់ហើយបញ្ជូនមកត្រឹមរបងស-២១ ឬក៏យ៉ាងម៉េច?

ហ៊ុយ ចូលត្រឹមកន្លែងផ្ទះគេស្នាក់ ព្រោះគេមិនឲ្យចូលមកដល់ខាងក្នុងទេ ។

ទ្រី ខ្ញុំចង់ឲ្យពូនឹកម្តងទៀតមើល នៅក្រោយ១៧មេសា មានធ្វើពិធីបុណ្យកងទ័ពនៅស្តាតគឺនៅ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ៧៥ ហើយ ប៉ុល ពត អ្នកឡើងនិយាយអំពីជ័យជំនះ១៧មេសា ដែរ ។ អ៊ីដែលពូនិយាយម៉ិញនៅក្នុងឆ្នាំ៧៥ ឬ ៧៦?

ហ៊ុយ ទេ ព្រោះកាលណឹងខ្ញុំនៅដេកពេទ្យដែរទេ ។ ខ្ញុំបន្ទាប់ពី១៧មេសា ខ្ញុំរបួស ។

ទ្រី កាលណឹងធ្វើតែកងទ័ពទេ ប្រហែលជាបីពាន់នាក់ មកពីកងពល មកពីកងវរសេនាធំ?

ហ៊ុយ កាលណឹងមានកម្មករអីណា មានតែកងទ័ពទេ ។

ទ្រី កាលដែលពូទៅយាមនៅស្តាតនៅឆ្នាំណា?

ហ៊ុយ ចាំមើល៍, ថ្ងៃ១៧មេសា ខ្ញុំត្រូវរបួសជេកពេទ្យប្រហែលជា៤ខែ។ បន្ទាប់មកទៀតទៅយាមនៅរដ្ឋករទឹកល្អក់។ ដល់ក្រោយមកទៀតគេឲ្យទៅធ្វើស្រែ។ ហើយដល់ថៃ១៧បុណ្យគេណឹងបានគេឲ្យទៅយាម។

## វគ្គទី៧

ភ័ណ្ណ កាលដែលពូទៅមន្ទីរ១៥ ពូទៅធ្វើអីដែរ?

ហ៊ុយ ខ្ញុំទៅដោះពួកកងរយ កងហារដែលគេចាប់ដាក់គុក។

ភ័ណ្ណ នៅខែណាដែរ?

ហ៊ុយ ឆ្នាំ៧៧ ប៉ុនមិនដឹងដើមឆ្នាំឬចុងឆ្នាំ ព្រោះតាម៉ុន ហៅពួកខ្ញុំ៤,៥នាកទៅជាមួយគាត់។ ខ្ញុំទៅថ្ងៃរសៀល ហើយជិតយប់មកវិញ។

ភ័ណ្ណ ពូមានឮដំណឹងដែលគេថា មានអ្នកល្បីៗ អ្នកសិល្បៈ ត្រូវគេបញ្ជូនទៅមន្ទីរ១៥ដែរ?

ហ៊ុយ ខ្ញុំអត់ដឹងទេ។

ភ័ណ្ណ ដូចជា គង់ សំអឿន។

ហ៊ុយ អត់ដែលស្គាល់ផង មិនដឹងគង់សំអឿនមុខយ៉ាងម៉េចផង។

ភ័ណ្ណ ធ្លាប់ឮពី ស៊ិន ស៊ីសាមុតដែរ?

ហ៊ុយ ស៊ិន ស៊ីសាមុត ខ្ញុំធ្លាប់ឮតែឈ្មោះ តែមិនដែលឃើញមុខផង។

វណ្ណៈ ពូទៅដោះអ្នកណានៅមន្ទីរ១៥ណឹង ហើយមាននៅឆ្នាំឈ្មោះដែរ?

ហ៊ុយ កងរយ និងកងហារ តែភ្លេចឈ្មោះអស់ហើយ បើឃើញមុខបានស្គាល់។

វណ្ណៈ ហេតុអីបានជាគេឲ្យទៅដោះ?

ហ៊ុយ តាម៉ុន ហៅខ្ញុំទៅ។

វណ្ណៈ ហើយអ្នកណឹងយ៉ាងម៉េចបានជាទៅជាប់នៅមន្ទីរ១៥?

ហ៊ុយ យុទ្ធជនធ្វើស្រែនៅព្រៃស នាំគ្នារត់ទៅផ្ទះ តែមិនដឹងប៉ុន្មាននាក់ទេ។ ដល់ហើយ កងរយៗ និងកងហារខ្លាច តាហ៊ុយ ដាក់វិន័យគាត់ក៏ទៅតាមរកគេរហូត។ ដល់តែទៅគេចាប់ដាក់នៅមន្ទីរ១៥ណឹងប៉ុន្មានថ្ងៃ ក៏គេរាយការណ៍ឲ្យដឹង។ បាន តាឌុច នេះឲ្យ តាម៉ុន យកកម្លាំងទៅដោះយកមកវិញ។

វណ្ណៈ ទៅដោះប៉ុន្មាននាក់ក្រៅពីពូ និង មុន?

ហ៊ុយ ខ្ញុំមិនដឹងអ្នកណាខ្លះទៀតទេ មានអ្នកបើកឡានម្នាក់ទៀត ។ តែទាំងអស់៤,៥នាក់ណោះ ។

ទ្រី ពេលដែលពូឆ្លងទូក ពួចតឡានទុកនៅកន្លែងណា?

ហ៊ុយ ទុកនៅនឹងផ្លូវក្បែរមន្ទីរពេទ្យ ។

វណ្ណៈ ពូបញ្ជាក់ពីអធិកាពរបស់ពូយ៉ាំងម៉េច បានជាខាងមន្ទីរ១៥ទទួលស្គាល់ពូ ហើយយល់ព្រមដោះអ្នកទាំងនោះមកវិញ?

ហ៊ុយ តាម៉ុន ធ្លាប់ទាក់ទងជាមួយគេ ធ្លាប់ស្គាល់គេពីមុនមក ដល់ចឹងគាត់ហៅពួកខ្ញុំការពារគាត់ ។ ដល់ចឹងគាត់ទាក់ទងគ្នាគាត់អាចដោះបាន ។

វណ្ណៈ តាម៉ុន រាយការណ៍ថា គាត់មកពីស-២១ដែរឬក៏យ៉ាំងម៉េច?

ហ៊ុយ ណឹងហើយ ចុះសំបុត្រ តាឌុច ឲ្យទៅ ។

វណ្ណៈ សំបុត្រប៉ុន្មានសន្លឹក?

ហ៊ុយ ខ្ញុំមិនដឹងដែរ ។ តែទាល់តែមានបញ្ជាពី តាឌុច ទើបអាចដោះបាន ។

ទ្រី ពេលដែលពូឆ្លងទូកហើយ ទៅជាមួយតាម៉ុន តើពូជួបអ្នកណាដំបូង?

ហ៊ុយ គាត់ជួបជាមួយប្រធានគេនៅណឹង ខ្ញុំសុំតាម៉ុនទៅផ្ទះ ព្រោះគ្រាន់តែទៅដល់ណឹង ដឹងតែផ្ទះ ខ្ញុំនៅជិតណឹង ខ្ញុំសុំគាត់ទៅផ្ទះ ។

ទ្រី ប៉ុន្តែពូមានបានចូលទៅជាមួយ តាម៉ុន ជួបជាមួយប្រធាន១៥ដែរ?

ហ៊ុយ អត់ទេ ខ្ញុំអត់ទៅជួបទេ ។ តាម៉ុន គាត់ទៅជួបជាមួយប្រធាន ។

ទ្រី ប្រធាននៅណឹងឈ្មោះអីដែរ?

ហ៊ុយ ខ្ញុំមិនដឹងដែរ មិនដឹងឈ្មោះអីខ្លះដែរ ព្រោះកាលណឹងដូចជាអរពេក ក៏សុំគេទៅផ្ទះ ។ ម៉ុន ដល់តែក្រោយមកគេចាប់យកទៅសម្លាប់ចោលដែរណឹង ។

ទ្រី ម៉ុន ដូចជាគណៈទាក់ទងខាងទ័ពពីភ្នំពេញទៅតំបន់២៥ ។ ឆ្នាំណាដែលគេចាប់គាត់ ប៉ុន្មានខែបន្ទាប់ពីពូមកជាមួយគាត់?

ហ៊ុយ កាលណឹងដូចជាឆ្នាំ៧៨ ។

វណ្ណៈ ម៉ុន មានតួនាទីសំខាន់នៅក្នុងកងពល ឬក៏នៅស-២១?

ហ៊ុយ ស-២១ ។

ទ្រី ម៉ុន ដូចតាមមើលនៅ៧០៣?

ហ៊ុយ បាទ! ចេញពី៧០៣ជាមួយខ្ញុំទាំងអស់ ពីមុនគាត់ជាប្រធានកងវរយ១២ ។ ការចាប់ខ្មាំង ជួនកាលមានការសហការជាមួយកងពល៧០៣ដែរ ។ ដូចថា គេហៅកម្លាំងខ្ញុំនៅស-២១ ឲ្យទៅជាមួយពួក៧០៣ ។ ចឹងពួក៧០៣ចាប់ហើយ បញ្ជូនមកឲ្យពួកខ្ញុំ ។

វណ្ណៈ ពេលដែលចាប់ខ្មាំង ពួកខាង៧០៣ចាប់តែមនុស្សនៅក្នុងអង្គភាពរបស់ខ្លួនឬក៏យ៉ាងម៉េច?

ហ៊ុយ ចាប់ខាង៧០៣ ចាប់ខាងបូព៌ា ចាប់ខាងឧត្តរ ។

វណ្ណៈ អ្នកណាដែលបញ្ជាធំនៅ៧០៣?

ហ៊ុយ មានតែ តាពីន និង តាណាត ។ តាណាត គាត់ប្រធានកងពល ដល់ហើយគាត់ទៅជំនួយការសេនាធិការ ក៏ឡើង តាពីន វិញ ។

ទ្រី កងចាប់នៅ៧០៣មានប៉ុន្មាននាក់?

ហ៊ុយ ទេ ខ្ញុំមិនដឹងដែរ ។

ទ្រី ចុះពូធ្លាប់ទៅដែរ?

ហ៊ុយ ខ្ញុំធ្លាប់ទៅ តែគ្នាគេត្រូវឲ្យអ្នកណាទៅ ដូចថាថ្ងៃនេះឈ្មោះនេះ ថ្ងៃក្រោយឈ្មោះនោះ ប៉ុន្មាននាក់ទៀត ។

ទ្រី អ្នកណាដែលចាប់ចែងពូឲ្យទៅ?

ហ៊ុយ ខាងនេះមាន តាឌុច និង តាហ៊ី ។

វណ្ណៈ ចុះខាង៧០៣?

ហ៊ុយ មានតែ តាពីន ។ ដូចថា កាលដែលពួក បងនួន នៅគឺពួកគាត់អ្នកចាប់ ។ ដល់ក្រោយមកពួក៧០៣ណឹងឆ្លើយដាក់បងនួន គេចាប់បងនួនវិញ ដល់ក្រោយមកវាមានអ្នកផ្សេងទៀត មានអ្នកផ្សេងទៀត ចឹងវាអត់ទៀង ស្រេចតែគេប្រើ អ្នកណាក៏គេប្រើកើតដែរ ។

វណ្ណៈ ចឹងខ្ញុំអរគុណហើយពូ ។

ចប់